សប្តាហ៍ទី
49

ភូមិក្រុមជំនុំដំបូង

អ្នកជឿនៅក្នុងក្រុមជំនុំដំបូងបានប្រមូលផ្តុំគ្នា ថ្វាយបង្គំព្រះជាម្ចាស់ ស្រឡាញ់គ្នាទៅវិញទៅមក ហើយចែករំលែកដំណឹងល្អអំពីព្រះយេស៊ូ!

តស់! យើងមករួមគ្នាបង្កើតភូមិក្រុមជំនុំដំបូងទាំងអស់គ្នា!

រឿងក្នុងព្រះគម្ពីរ

ទិដ្ឋភាពនៃក្រុមជំនុំដំបូង

ក្រោយពេលព្រះយេស៊ូយាងឡើងទៅស្ថានសួគ៌ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើពួកសិស្ស។ ពួកសិស្សបានផ្សព្វផ្សាយដំណឹងល្អយ៉ាងក្លាហាន ហើយមនុស្សជាច្រើនបានជឿលើព្រះយេស៊ូ ព្រមទាំងជួបជុំគ្នានៅក្រុមជំនុំ។ ពួកគេស្រឡាញ់គ្នា អធិស្ឋានរួមគ្នា កាច់នំប៉័ង និងសរសើរតម្កើងព្រះជាម្ចាស់។ ក្រុមជំនុំដំបូងបានរស់នៅដោយមានចិត្តតែមួយនៅក្នុងសេចក្តីជំនឿ។

«ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ។» [កិច្ចការ២:៤៦-៤៧]

សមិទ្ធផលសម្រេច



វត្ថុបំណង

- យល់ពីទិដ្ឋភាពនាសម័យក្រុមជំនុំដំបូង
- តុបតែងគំនូរផ្សេងៗ ដើម្បីរៀបចំផ្គុំជាភូមិមួយ
- សហការជាមួយមិត្តភក្តិ ដើម្បីបង្កើតភូមិមួយរួមគ្នាឱ្យបានសម្រេច
- ចងចាំថា ក្រុមជំនុំគឺការជួបជុំគ្នា ដើម្បីថ្វាយបង្គំ និងស្រឡាញ់ព្រះជាម្ចាស់។

សម្ភារៈ

- ក្រដាសធ្នាំងធំ
- ក្រដាសពណ៌
- ហ្វឺតពណ៌
- ស្តីគ័រស្អាតៗ (បើមាន)
- ខ្សែបូ (បើមាន)
- ការ
- កូល័រទៀន
- កន្ត្រៃ
- ខ្មៅដៃ

របៀបធ្វើសកម្មភាព

1. ត្រូវគូរព្រំាងទម្រង់ភូមិ និងរូបព្រះវិហារនៅចំកណ្តាល ព្រមទាំងគូររបងព័ទ្ធជុំវិញនៅលើក្រដាសធ្នាំងធំ ទុកជាមុនឱ្យហើយ។



2. គូររូបផ្ទះ ព្រះវិហារ ដើមឈើ អណ្តូងទឹក ហាងទំនិញ ។ល។ នាសម័យក្រុមជំនុំដំបូង រួចលាបពណ៌ឱ្យបានស្អាត។



3.

4. កាត់រូបគំនូរទាំងនោះចេញតាមគែម។



5. យករូបដែលកាត់រួច ទៅបិទនៅលើក្រដាសធ្នាំងធំរួមគ្នាដើម្បីបញ្ចប់ "ភូមិក្រុមជំនុំដំបូង" របស់យើង! រួចរាល់ហើយ!



ការពង្រីកសកម្មភាព

- សាកល្បងគូរ និងធ្វើរូបអគារប្លែកៗបន្ថែមទៀត ដើម្បីពង្រីកភូមិឱ្យកាន់តែធំ។
- គូររូបអ្នកជឿនាសម័យក្រុមជំនុំដំបូង រួចយកទៅបិទជាមួយគ្នា។
- ជជែកគ្នាជាមួយមិត្តភក្តិ អំពីចំណុចល្អៗរបស់ក្រុមជំនុំដំបូងដែលយើងចង់យកគំរូតាម។
- យកស្នាដៃដែលធ្វើរួច ទៅដាក់តាំងបង្ហាញនៅលើជញ្ជាំងថ្នាក់រៀន និងទស្សនារួមគ្នា។
- តស់! មកសាងសង់ក្រុមជំនុំដែលតែងតែជួបជុំគ្នា អធិស្ឋាន និងស្រឡាញ់គ្នា ដូចក្រុមជំនុំដំបូងដែរ!

Tip សម្រាប់គ្រូ

- គ្រូត្រូវគូរទម្រង់ភូមិ និងព្រះវិហារនៅចំកណ្តាល ទុកជាមុនឱ្យហើយ។
- សូមលើកទឹកចិត្តកុមារ ឱ្យគូររូបអគារ និងមនុស្សផ្សេងៗដោយសេរីតាមការស្រមើស្រមៃរបស់ពួកគេ។
- សូមរៀបចំជួយគូរ ឬផ្តល់គំនិតពីទម្រង់ប្លែកៗដូចជា ផ្ទះ ព្រះវិហារ ដើមឈើ អណ្តូងទឹក ចម្ការ និងហាងទំនិញ ជាដើម។
- ជួយបណ្តុះស្មារតីសហការ និងការចេះយោគយល់គ្នា។
- ក្រោយពេលធ្វើរួច សូមដឹកនាំកុមារអធិស្ឋានអរព្រះគុណព្រះជាម្ចាស់ដោយពោលថា "ពួកយើងសប្បាយចិត្តណាស់ ដែលបានធ្វើវារួមគ្នា!"។